ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម
លេខ : ០២៤/២១ ប.ស.ស.

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាព សម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## បេឡាជាតិសន្តិសុខសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- យោងតាមការចាំបាច់របស់បេឡាជាតិសន្តិសុខសង្គម

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត "ក្រុមការងារសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" សំដៅពិនិត្យលទ្ធភាពកែសម្រួល



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២៦ ០០ ០១ , ០២៣ ៨៨ ១០ ១៥ ០២៣ ៩៩ ៩២ ១៥ , ០២៣ ៨៨ ១០ ១៦
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

កញ្ចប់តាវកាលិកថៃទាំសុខភាពសម្រាប់សមាជិក ប.ស.ស. ក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ ឱ្យមានភាពសមស្របនឹងអត្រាភាគទានដែលត្រូវកែសម្រួល។

ក. សមាសភាពក្រុមការងារនេះមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ស្វួន ស៊ីឡៀង** | អគ្គនាយករងបេឡាជាតិសន្តិសុខសង្គម | ប្រធាន |
| ២-លោកស្រី **ម៉េត សុគន្ធឡាលីន** | ប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ | សមាជិក |
| ៣-លោកវេជ្ជ. **ទត ម៉ូឡារី** | ប្រធាននាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល | សមាជិក |
| ៤-លោក **សុភ មូរ៉ា** | ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម | សមាជិក |
| ៥-លោក **ហុខ សុខហៀប** | ប្រធាននាយកដ្ឋានបញ្ជិកានិងភាគទាន | សមាជិក |
| ៦-លោក **លៀង ពន្លក** | ប្រធាននាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម | សមាជិក |
| ៧-លោក **ស្រិល ស៊ីថាត** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ | សមាជិក |
| ៨-លោកស្រី **ណឹម ស្រីនាង** | ប្រធានការិយាល័យវាយតម្លៃហានិភ័យហិរញ្ញវត្ថុ | សមាជិកអចិន្ត្រៃយ៍ |

ខ. ក្រុមការងារនេះមានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងកំណត់កញ្ចប់ថ្លៃចំណាយព្យាបាលនិងថៃទាំវេជ្ជសាស្ត្រសម្រាប់អ្នកជំងឺកូវីដ-១៩ ដែលជាសមាជិក ប.ស.ស.
- សិក្សាស្រាវជ្រាវ និងកំណត់កញ្ចប់ថ្លៃសេវាបង្ការសុខភាពក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩
- រៀបចំទិន្នន័យតាវកាលិកសន្តិសុខសង្គមផ្នែកថៃទាំសុខភាពសម្រាប់ដំណើរការវិភាគហានិភ័យហិរញ្ញវត្ថុ
- សិក្សាស្រាវជ្រាវ និងវិភាគបញ្ហាឱនភាពថវិកាផ្នែកថៃទាំសុខភាពធៀបនឹងអត្រាភាគទាននាពេលបច្ចុប្បន្ន
- កំណត់បញ្ហាអាទិភាពដើម្បីធ្វើការកែសម្រួលអត្រាភាគទានផ្នែកថៃទាំសុខភាព
- កំណត់ចំនួនអត្រាភាគទានដែលត្រូវស្នើសុំកែសម្រួល
- ប្រជុំត្រួតពិនិត្យសម្រេចលើរបាយការណ៍សិក្សាស្រាវជ្រាវមុនដាក់ជូនអគ្គនាយក ប.ស.ស. ពិនិត្យសម្រេច
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ២** .-

សមាជិកក្រុមការងារសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថៃទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៣** .-

ការិយាល័យវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃនាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ ជាសេនាធិការឱ្យក្រុមការងារនេះសម្រាប់កិច្ចការដូចខាងក្រោម៖

- រៀបចំសំណុំឯកសារសម្រាប់ការប្រជុំរបស់ក្រុមការងារ
- រៀបចំលិខិតអញ្ជើញ និងរបៀបវារៈសម្រាប់កិច្ចប្រជុំតាមការកំណត់របស់ប្រធាន
- រៀបចំកិច្ចប្រជុំរបស់ក្រុមការងារ
- ធ្វើកំណត់ហេតុនិងរបាយការណ៍កិច្ចប្រជុំរបស់ក្រុមការងារ
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាន។

**ប្រការ៤** .-

ចំណាយរដ្ឋបាលលើការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារសិក្សាលទ្ធភាពកែសម្រួលអត្រាភាគទានផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាបន្ទុករបស់ ប.ស.ស.។

**ប្រការ៥** .-

ឯកឧត្តម លោក លោកស្រី ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១១ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០២១

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**អ៊ុក_សមវិទ្យា**